ព្រះរាជាណាចក្រកម្ពុជា

**តុលាការកំពូល** ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី ៣៣*៧៧

លេខៈ ០៦

ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៤ **នាមនាមប្រជារាស្ត្រខ្មែរ**

<u>សាលដីកា</u> **តុលាការកំពូល**

លេខៈ ២៤៧ បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០០៤

ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ :

១-ឯកឧត្តម **ខិត មុន្នី** ជាប្រធាន

២-លោក ស៊ិន ឌីម ជាចៅក្រមរបាយការណ៍

៣-លោក ប្រាក់ គឹមសាន ជាចៅក្រម

៤-លោក ជីវ កេង ជាចៅក្រម

៥-លោក សោម សិរីវឌ្ឍ ជាចៅក្រម

លោក **សុខ រម៉ា** ក្រឡាបញ្ជី

តំណាងមហាអយ្យការ

ឯកឧត្តម **ជួន ស៊ុនឡេង** ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ៩២"ច"ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៤៤៩ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ **តូច វណ្ណថា** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣៣ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើការអង្គការប្រាសាក់តាកែវ ទីលំនៅភូមិថ្នល់បែក ឃុំរកាក្រៅ ស្រុកដូនកែវ ខេត្តតាកែវ ។ ឪពុកឈ្មោះតូច ឆាន "ស" ម្តាយឈ្មោះមាស សាផុន "រ" ប្រពន្ធឈ្មោះប៉ែន ពុទ្ធារី មានកូន០២នាក់ ។

មានមេធាវីលោក កែវ យ៉ា ។

ចុងចម្លើយឈ្មោះ **សុខ ចាន់រ៉ុង**(ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣៣ឆ្នាំ មុខរបរ ធ្វើការទីស្តីការគណៈរដ្ឋមន្ត្រី ទីលំនៅផ្ទះលេខ ៣៧២ ផ្លូវ២៧១ សង្កាត់ទំនប់ទឹក ខ័ណ្ឌ

ចំការមន ក្រុងភ្នំពេញ ។ ឪពុកឈ្មោះសុខ ក្រែប "ស" ម្តាយឈ្មោះកៅ ធា "រ" ។

មានមេធាវីលោក ខូវ ចន្ថា ។

**កម្មវត្ថុបណ្តឹង** : ប្តឹងទាមទារដីកម្មសិទ្ធិ .

បានឃើញបណ្តឹងសាទុក្ខលេខ ៣៤៨ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ឈ្មោះតូច វណ្ណថា ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៩២"ច" ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ០៦ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៤ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងរបស់ដើមចោទចុះថ្ងៃទី២១-២-២០០០ បានប្តឹងទាមទារដីកម្មសិទ្ធិដោយសំអាងហេតុថា : កាលពីឆ្នាំ១៩៩១ ខ្លួនបានដេញថ្លៃទិញដីពីរដ្ឋបានមួយឡូរ៍ ខាងត្បូងផ្សារតាកែវ ក្នុងតំលៃ ៦.០០០ដុល្លាអាមេរិក ហើយខ្លួនក៏បានកាន់កាប់រហូតមក គឺដីឡូត៍ប្លង់លេខ ១៧០ ស្ថិតនៅក្នុងភូមិថ្នល់បែក ឃុំរការក្រៅ ស្រុកដូនកែវ ។ មកដល់ឆ្នាំ១៩៩៥ ខ្លួនក៏បានដាក់ពាក្យសុំកាន់-កាប់កន្លែងដីទំនាស់នេះដែលមានប័ណ្ណសំគាល់សិទ្ធិលេខJ១២-១៣៤៨ ចុះថ្ងៃទី៧-០១-១៩៩៥ ។

កន្លងមកក្នុងកំឡុងឆ្នាំ១៩៩២ ចុងចម្លើយបានបោះបង្គោលរបងចូលមកដីខ្លួនប្រហែល២ម លុះមកដល់ឆ្នាំ១៩៩៩ ខែ៥ ចុងចម្លើយបានព័ទ្ធរបងយកដីខ្លួន កន្លែងដីទំនាស់នេះតែម្តង ខ្លួនបានរាយការណ៍ជូនទៅថ្នាក់ស្រុក ដើម្បីដោះស្រាយ តែពេលដោះស្រាយចុងចម្លើយពុំចូលរួមទេ ហើយស្រុកក៏បានហាមឃាត់ ចុងចម្លើយមិនឱ្យធ្វើសកម្មភាពកន្លែងដីទំនាស់នេះទេ តែចុងចម្លើយពុំព្រមស្តាប់ហើយក៏បានប្តឹងផ្តល់គ្នា មកដល់ទីនេះ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ២៩"ខ"ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០១ របស់តុលាការខេត្តតាកែវ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះតូចវណ្ណថា ចុះថ្ងៃទី២១-២-២០០០ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិរបស់លោក សុខ ឡេង ចម្លើយឱ្យមកលោកសុខ ដារ៉ាវុធ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

៣-ទទួលស្គាល់ប័ណ្ណសំគាល់កាន់កាប់ដីធ្លីលេខ $J_{12}$-១៣៤៨ ចុះថ្ងៃទី០៧-០១-១៩៩៥ របស់ឈ្មោះតូច វណ្ណថា ទុកជាត្រឹមត្រូវតាមច្បាប់ ។

៤-បង្គាប់ឱ្យចម្លើយរុះរើរបង និងសំណង់ផ្សេងៗចេញពីដីទំនាស់ចាប់ពីថ្ងៃក្រោយ

សាលក្រមនេះ មានអានុភាពអនុវត្ត ។

៥-បង្គាប់ឱ្យចម្លើយបង់ប្រាក់ប្រដាប់ក្ដី គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្វ៊ីងចំនួន ១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះចំនួន៥.០០០៛ សរុបចំនួន ៧.០០០៛ ។ ប្រាក់នេះបានកាត់យក ដើមចោទបានបង់ទុករួចហើយ កាលបើផុតកំណត់ប្ដឹងឧទ្ធរណ៍ ឱ្យចម្លើយបង់ប្រាក់ចំនួន ៧.០០០៛នេះ ទៅដើមចោទវិញ និងឱ្យបង់ពន្ធសមាមាត្រ១%លើប្រាក់ថ្លៃដី ៤១ជី .ប្រាក់១% នេះ ៨០% សំរាប់ជាថវិការដ្ឋ និង២០% សំរាប់រង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស។

សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្ដី ទុកសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ១០៤ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ របស់ឈ្មោះ សុខ ដារ៉ាវុធ ប្ដឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ២៩"ខ"ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ ២០០១ របស់តុលាការខេត្តតាកែវ ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៩២"ច" ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី២២-១១-២០០១ របស់ឈ្មោះសុខដារ៉ាវុធ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ២៩"ខ"ចុះថ្ងៃទី២១-១១-២០០១របស់តុលាការខេត្តតាកែវ ចោលជាអសារបង់ ។

៣-ប្រគល់ដីទំនាស់ឡូត៍លេខ ១៧០ ទំហំ ៨៤ម៉ែ ស្ថិតនៅមុខផ្សារតាកែវដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ J ១២-១៣៤៨ ចុះថ្ងៃទី៧-០១-១៩៩៥ ឱ្យទៅចុងចម្លើយឈ្មោះសុខ ឡេង ដែលមានឈ្មោះសុខ ដារ៉ាវុធ ជាតំណាងកាន់កាប់គ្រប់គ្រងប្រើប្រាស់តទៅ ។

៤-បង្គាប់ឱ្យមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដីខេត្តតាកែវ កាត់ប្ដូរឈ្មោះក្នុងប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ J12-១៣៤៨ ចុះថ្ងៃទី០៧-០១-១៩៩៥ ពីឈ្មោះតូច វណ្ណថា មកឈ្មោះសុខ ឡេង វិញ ចាប់ពីពេលដែលសាលដីកានេះ ចូលជាស្ថាពរ ។

៥-ទុកសិទ្ធិឱ្យដើមចោទឈ្មោះ តូច វណ្ណថា ប្ដឹងទាមទារប្រាក់ថ្លៃទិញដីទំនាស់នេះពីអាជ្ញាធរខេត្តតាកែវវិញ ។

៦-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្លឹង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ៥០០០៛ ចំណាយលើអាជ្ញាធរតុលាការ៥.០០០៛ សរុប១៣.០០០៛ និងបង្គាប់ឱ្យដើមចោទបង់ពន្ធសមាមាត្រ ១ភាគរយលើថ្លៃដីទំនាស់ ។

៧-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី ។

បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣៤៨ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ឈ្មោះតូច-វណ្ណថា ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៩២"ច" ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៤ របស់ឈ្មោះតូច វណ្ណថា ។

បានឃើញសារណាតបចុះថ្ងៃទី១៨ ខែមិនា ឆ្នាំ២០០៤ របស់ឈ្មោះសុខ ដារ៉ាវុធ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : ដីនេះដើមចោទទិញពីអាជ្ញាធរមានសមត្ថកិច្ចប្រកាសដេញថ្លៃលក់ត្រឹមត្រូវតាមនីតិវិធី ហេតុនេះដើមចោទទិញដីនេះមានតំលៃផ្លូវច្បាប់ហើយ បើចុងចម្លើយថា ខ្លួនកាន់កាប់រហូតម្តេចមិនប្តឹងតវ៉ា បើបដិសេធការលក់ទិញនេះនាំឱ្យអង្គភាពសាធារណៈអស់ប្រសិទ្ធិភាពក្នុងការគ្រប់គ្រងហើយ ឯចុងចម្លើយមានសិទ្ធិប្តឹងទារសំណងពីរដ្ឋទៅ ម៉្យាងទៀតដីនេះមានប័ណ្ណកម្មសិទ្ធិទៀត បើតុលាការមោឃៈការទិញលក់រវាងរដ្ឋអំណាច និងដើមចោទ នាំឱ្យគេលែងទុកចិត្តលើរដ្ឋ ហើយមានទំនាស់ច្បាប់ច្រើនណាស់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ តូច វណ្ណថា នាពេលសវនាការថា : សលាឧទ្ធរណ៍សំរេចមិនយុត្តិធម៌ទេ ដីនេះខ្លួនទិញត្រឹមត្រូវតាមច្បាប់ពីអាជ្ញាធរមានសមត្ថកិច្ច ពេលទិញហើយទើបចុងចម្លើយបំពានរំលោភកាន់កាប់ឆ្នាំ១៩៩២ ធ្វើរបងទៀត ពេលទិញដីនេះទំនេរទេ គ្មានផ្ទះគឺជាកន្លែងចាក់សំរាម ដល់ឆ្នាំ១៩៩៩ គេបំពានរំកិលយកដីខ្លួនតែម្តង ធ្វើផ្ទះ និងចាក់ដីតែល្ងាចថ្ងៃសុក្រទេ ហើយពេលយប់ទៀត ។ ពេលទិញហើយ ខ្លួនបានបោះរបង និងដាំដើមឈើបន្តិចបន្តួចតែងាប់អស់ទៅវិញ មុនខ្លួនទិញដីនេះរដ្ឋបានប្រកាសដេញថ្លៃតាមនីតិវិធី មានប្លង់ និងបានបិទប្រកាសត្រឹមត្រូវមានមនុស្សច្រើនដេញដែរ តែខ្លួនដេញបាន ហើយធ្វើប័ណ្ណកម្មសិទ្ធិ ។ ខ្លួនសូមបដិសេធសាលដីកាសាលាឧទ្ធរណ៍ និងសុំឱ្យសាលាឧទ្ធរណ៍ជំនុំជំរះឡើងវិញ សុំគ្រប់គ្រងដីធ្វើកម្មសិទ្ធិ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ សុខ ដារ៉ាវុធ នាពេលសវនាការថា : ខ្លួនតំណាងឱ្យម្តាយផ្ទាល់ ដីនេះគ្រួសារខ្លួនរស់នៅតាំងពីឆ្នាំ១៩៧៩ មក មានទំហំ ៣.០០០ម$^{២}$ នៅឆ្នាំ១៩៨១ រដ្ឋបានយកពាក់កណ្តាល ឆ្នាំ១៩៨៧ គាត់យក ១ហ៉ាត ទៀត យកធ្វើផ្សារ ហើយថា ខេត្តមានគោលនយោបាយដោះដូរ តែមិនដោះដូរសោះ តើខេត្តធ្វើប្លង់របៀបណា ? បើដីខ្លួនរស់នៅរហូតមានផ្លូវ

ខ្មោចជីតាខ្លួនទៀតផង ក្រោយមកជូនដំណឹងឱ្យខ្លួនរុះរើ គេរុះមិនបានឱ្យដើមចោទប្តឹងតុលាការ ខ្លួនយល់ថា សាលាឧទ្ធរណ៍សំរេចត្រឹមត្រូវហើយ បើដកដីនេះ លុះណាមានថ្លៃរបច្ចុប្បន្ន ដីខ្លួនសល់តែ ១៣០០ម៉ែ ទេ សូមជួយរកយុត្តិធម៌ផង ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក កែវ យ៉ា ជាមេធាវីការពារឱ្យឈ្មោះតួច វណ្ណថា បានលើកឡើងថា : ក្នុងនាមខ្លួនជាមេធាវីចំណាយក្តីឱ្យដើមចោទ សូមលើកសំណួរបីចំពោះលោក សុខ ដារ៉ាវុធ ក្នុងពេលនេះថា :

១-គាត់ថា បានទាមទារដីឡូត៍ពីរដ្ឋ តើទាមទាររបៀបណា ?

២-ដីគាត់មានប៉ុន្មានឡូត៍ លេខប៉ុន្មាន ?

៣-សូមបង្ហាញថា ខ្លួនបានដីដោយមិនបានបង់លុយ ?

បានស្តាប់ចម្លើយរបស់លោក សុខ ដារ៉ាវុធ តបថា : ដីខ្លួនមានពីរប្លង់ គេដេញបាន គេមិនយក ក៏ប្រគល់ឱ្យខ្លួនវិញ ។ ឯទំហំដីខ្លួនមិនដឹងទេ ខ្លួនដឹងផ្ទៃក្រឡាទូទៅ ចំពោះតំលៃ ដើមចោទថា ទិញដីនេះ៦.០០០ដុល្លាអាមេរិក តែដីនេះមានតំលៃពិតប្រាកដតែ១៨០០ដុល្លាអាមេរិកទេ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកកែវ យ៉ា បានបន្ថែមទៀតថា : សុខ ដារ៉ាវុធ ថា ដីខ្លួនមានពីរប្លង់ មួយប្លង់គេបោះបង់ចោល ហើយឱ្យគាត់វិញ ប៉ុន្តែដីនេះ នួន ស្រ៊ីម បានទទួលស្គាល់ថា ជាដីរបស់តួច វណ្ណថា ទេ តំលៃមានបញ្ជាក់ក្នុងសំណុំរឿងស្រាប់ សាលាឧទ្ធរណ៍សំរេចមិនបានត្រឹមត្រូវទេ ដីនេះតួច វណ្ណថា បានទិញពីអាជ្ញាធរដែលប្រកាសលក់ដេញថ្លៃត្រឹមត្រូវ បង់លុយជូនរដ្ឋ ពេលវាស់វែងធ្វើប្លង់ អ្នកមានព្រំប្រទល់ផ្តិតមេដៃឱ្យទៀត ម្តេចចុងចម្លើយមិនតវ៉ា រហូតកូនក្តីខ្លួនមានប្លង់កម្មសិទ្ធិឯកសារមានហើយ អាជ្ញាធរស្រុកបញ្ជាក់ហើយ ពេលដេញថ្លៃទិញដីនេះ គ្មានផ្ទះ គ្មានរបងទេ ចុងចំលើយបំពានពេលកូនក្តីខ្លួនទិញដីបាន ។ ខ្លួនសូមឱ្យព្រះរាជអាជ្ញាជួយប្តឹងការពារផលប្រយោជន៍ ព្រោះដីនេះ តួច វណ្ណថា បានទិញពីរដ្ឋ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ខូវ ចន្ថា ជាមេធាវីចំណាយក្តីឱ្យចុងចម្លើយ បានលើកឡើងថា : ដីនេះកូនក្តីខ្លួនបានរស់នៅកាន់កាប់ពីឆ្នាំ១៩៧៩មក ជាដីកំណើតខ្លួនផង ការរស់នៅរបស់ចុងចម្លើយ ស្របតាមច្បាប់ភូមិបាល និងអនុក្រឹត្យលេខ ២៥អនក្រ ហេតុដូច្នេះ បើចង់ឱ្យចុងចម្លើយចេញ លុះណាមានការដោះដូរនិងឯកភាពពីចុងចម្លើយ ។ ខ្លួនយល់ថា សាលាឧទ្ធរណ៍សំរេចត្រឹមត្រូវហើយ ។

ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់ចម្លើយគូភាគី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីគូភាគី .

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៤៨ ចុះថ្ងៃទី១៧-១១-២០០៣ របស់លោក តូច វណ្ណថា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាម មាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការលើកឡើងក្នុងសារណាចុះថ្ងៃទី១៥-០២-២០០៤ របស់ដើមចោទ ថា ដីទំនាស់នេះស្ថិតនៅក្នុងគំរោងសាងសង់ផ្សារ ចំណតរថយន្ត និងផ្ទះល្វែងតាំងពីឆ្នាំ១៩៨៤-១៩៨៧ ហើយចាប់ផ្តើមអនុវត្តនៅឆ្នាំ១៩៩២ ដោយលោកបានដេញថ្លៃទិញពីទីរួមខេត្តដោយមាន ការយល់ព្រមពីគណៈអចិន្ត្រៃយ៍ខេត្តតាកែវនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះ ដីទំនាស់នេះចុង ចម្លើយបានកាន់កាប់តាំងពីឆ្នាំ១៩៧៩ មក ម្យ៉ាងទៀត ក្នុងពេលដែលអាជ្ញាធរធ្វើការដេញថ្លៃលក់ដី ដីទំនាស់នេះ គឺឋិតនៅក្រោមអនុភាពនៃអនុក្រឹត្យ២៥ អនក្រ ចុះថ្ងៃទី២២-៤-១៩៨៩ និងសេចក្តី ណែនាំលេខ ០៣ ចុះថ្ងៃទី០៣-៦-១៩៨៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីរួចទៅហើយ ដូច្នេះអាជ្ញាធរខេត្ត មិនអាចរឹបអូសយកដីនេះដោយពុំបានផ្តល់សំណងចិត្តសមស្របឱ្យចុងចម្លើយឡើយ ។ ចុងចម្លើយ មាន សិទ្ធិលើដីទំនាស់នេះ តាមមាត្រា៦២និង៧៤ នៃច្បាប់ភូមិបាលហើយ ។ រីឯការទិញលក់រវាង ដើមចោទ និងអាជ្ញាធរទីរួមខេត្ត ត្រូវទុកជាមោឃៈតាមមាត្រា ៣៥ នៃក្រឹត្យច្បាប់លេខ៣៨ក្រច ចុះថ្ងៃទី២៨-១០-១៩៨៨ និងតាមមាត្រា ១៨០ នៃច្បាប់ភូមិបាលចាស់ ។

- យល់ឃើញថា លោក ស៊ូ ភិរិន អភិបាលខេត្តក៏ទទួលស្គាល់ការកាន់កាប់របស់ចុង ចំលើយតាមរយៈលិខិតលេខ ៣៦ របក ចុះថ្ងៃទី២៤-១២-១៩៩៧ ដែរ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៩២"ច" ចុះថ្ងៃទី២៤-១០-២០០៣ របស់ សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់និងគតិច្បាប់ហើយ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី**

១-ទទួលបណ្តឹងសាទុក្ខលេខ៣៤៨ចុះថ្ងៃទី១៧ខែវិច្ឆិកាឆ្នាំ២០០៣ របស់លោកតូចវណ្ណថា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ៩២"ច" ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៣ របស់ សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីដែលដើមចោទ បានបង់ទុកនៅតុលាការកំពូលចំនួន១៩.០០០រៀល:

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្វ៊ីងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០រ សរុប ១៩.០០០រៀល .

បង្គាប់ឱ្យដើមចោទបង់ពន្ធសមាមាត្រតាមការកំណត់របស់តុលាការសាលាឧទ្ធរណ៍ ។

៤-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០០៤ ។